This project is co-funded by:

## F2F group 3 Sustainable Agriculture training report:

The training was orgnaised from 30 Aug – 02 Sept 2011 in Kampong Thom province. There are five CNFSC members attended in this training, KAFDOC, CWDCC, KIPD, CHRD, and KABB.

# កំណត់ហេតុ

# ស្តីពី

# វគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្មនិរន្តរភាព ដល់កសិករគំរូក្រុមទី៣



## ថ្ងៃទី៣០ សីហា ដល់ ថ្ងៃទី០១ កញ្ញា ឆ្នាំ២០១១

## ទីកន្លែង: កាកបាទក្រហមកម្ពុជា ខេត្តកំពង់ធំ

**កំណត់ហេតុ**

**ស្តីពី**

**វគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្មនិរន្តរភាព ដល់កសិករគំរូក្រុមទី៣**

**ថ្ងៃទី៣០ សីហា ដល់ ថ្ងៃទី០២ កញ្ញា ឆ្នាំ២០១១**

**ទីកន្លែង: ភាគបាទក្របាមកម្ពុជា ខេត្តកំពង់ធំ**

នៅថ្ងៃទីម្ភៃប្រាំបួន ខែសីហា ឆ្នាំពីរពាន់ដប់មួយ ក្រុមស្នូលសន្តិសុខស្បៀងបានបើកវគ្គបណ្តុះបណ្តាលពីការងារកសិកម្ម ដល់កសិករគំរូក្រុមទី៣ ដែលមកពីអង្គការចំនួន៦ (KIPD KDDF KAFDOC KABB CWDCC PWHO ) ហើយវគ្គនេះធ្វើឡើងនៅខេត្តកំពង់ធំ។ ក្នុងវគ្គនេះត្រូវបានសម្របសម្រួលដោយ អ្នកស្រី **ស៊ិន ស៊ីណេន** លោក **សុខ រឿន** និង លោក **អ៊ូត ឡុង** ដែលជាសមាជិកក្រុមគាំទ្របច្ចេកទេស ។ ជាដំបូងអ្នកស្រី **ស៊ិន ស៊ីណេន** និង លោក **អ៊ូត ឡុង** បានរៀបចំបទបញ្ជាផ្ទៃក្នុងដែលមានដូចខាងក្រោម:

**<u>បទបញ្ជាផ្ទៃក្នុង:</u>**

- ចូលម៉ោង ៧:៣០នាទី ចេញ ម៉ោង ១១:៣០នាទី
- សំរាកអាហារសំរ៉ន់ ៩:៣០ –១០:០០នាទី
- ពេលរសៀលចូលម៉ោង ១:៣០ ចេញម៉ោង ៥:៣០នាទី
- ហាមជក់បារីក្នុងបន្ទប់
- និយាយទូរស័ព្ទហាមចេញទៅក្រៅ ឬ បិទសំលេងរោទិ៍
- ពេលរៀនហាមនិយាយកាត់
- ត្រូវមានសំណួរ ឆ្លល់លើកដៃ
- អ្នកមកយឺតពេល ក្រុមធំធ្វើការពិន័យ

ការណែនាំខ្លួន ដោយរៀបរាប់ពីឈ្មោះ តួនាទី មកពីកន្លែងណា?

ការបង្ហាញពីគោលបំណង របស់ **អ្នកស្រី ឆឹម គឹមហេន :**

១ – ពង្រឹងសមត្ថភាពកសិករលើការប្រើប្រាស់ធនធានធម្មជាតិនៅជុំវិញផ្ទះ និង ការប្រើប្រាស់ដីឱ្យអស់លទ្ធភាពតាមរយៈការធ្វើកសិកម្មចំរុះ

២– បង្កើនប្រាក់ចំណូលដល់គ្រួសារកសិករក្រីក្រ និងកាត់បន្ថយការចំណាយ ដែលមិនចាំបាច់ ដើម្បីផ្សារភ្ជាប់ជាមួយការងារកសិកម្ម

៣ – ចងបណ្តាញជាមួយអង្គការដៃគូរដើម្បី ធ្វើការតាមដាន និង អនុវត្តការងារកសិកម្មចំរុះ

បន្ទាប់មក លោកស្រី **ស៊ិន ស៊ីណន** បានសម្របសម្រួលដើម្បី ធ្វើការរំពឹងទុករបស់អ្នកចូលរួម ដោយចែកក្រដាសពណ៌ឱ្យម្នាក់មួយសន្លឹកដើម្បីសរសេរនូវអ្វីដែលពួកគាត់ចង់បាន បន្ទាប់មកបូកសរុបដាក់នៅលើក្រដាសផ្ទាំងធំ បង្ហាញដល់ក្រុមធំ:

- នឹងចេះ ធ្វើជីកំប៉ុស្ត និង ជីកំប៉ុស្តទឹក ចេះដាំដំនាំ ចេះចិញ្ចឹមសត្វ និងអាចចែករំលែកដល់កសិករក្នុងសហគមន៍
- របៀបធ្វើជីអ៊ីអឹម
- របៀបធ្វើថ្នាំបណ្តេញសត្វល្អិត
- របៀបរៀបចំសួនពហុប្រយោជន៍
- របៀបរក្សា និង បណ្តុះផ្សិត
- បច្ចេកទេសដាំឈើពហុប្រយោជន៍
- ចេះ ធ្វើផែនការកសិករនីមួយៗ
- នឹងធ្វើការបង្ហាញដល់កសិករតាមភូមិគោលដៅ
- មានជំនាញ និង ចំណេះដឹងផ្នែកកសិកម្មច្បាស់លាស់ដើម្បីចែករំលែកដល់សហគមន៍ឱ្យបានចេះដឹងទាំងអស់គ្នា និងមានជីវភាពប្រសើរឡើង
- ចេះពីវិធីសាស្ត្រក្នុងការចិញ្ចឹមមាន់ និង បណ្តុះផ្សិត
- បានរៀនសូត្រជាក់ស្តែងពីកសិករ
- នឹងក្លាយទៅជាអ្នកគំរូរគេនៅក្នុងសហគមន៍
- ចេះដាំដំណាំតាមរដូវកាល

ក្រោយពីយើងបានអាននូវការរំពឹងទុករបស់បងប្អូនរួចមកឃើញថា ការរំពឹងទុកនេះផ្តោតទៅលើការងារកសិកម្ម ដែលមិនខុសពីខាងខ្ញុំរំពឹងទុកនោះទេ។ ហើយយើងបានយល់ទាំងអស់គ្នា ថាចប់វគ្គនេះរយៈ៣ថ្ងៃទៅ យើងនឹងធ្វើអ្វីបន្តទាំងអស់គ្នា។ បន្ទាប់មកអ្នកស្រីក៏បាននាំរំលឹក និង ធ្វើការឆ្លុះបញ្ចាំងពីលទ្ធផលពីការងាររបស់កសិករគំរូរក្រុមទី៣ បន្ទាប់ពីការប្រជុំនៅខេត្តកោះកុងដែលមានដូចខាងក្រោម:

**KABB**

- **ធីវ វិត (ប):** ផែនការមាន៣ ស្ទូងស្រូវ ដាំស្ពៃ ធ្វើទ្រុងមាន់ បានធ្វើទាំងអស់។
- **ម៉ើន នាង (ស):** ផែនការមាន៣ ធ្វើជីកំប៉ុស្តគោក មិនបានធ្វើទេតែធ្វើជីកំប៉ុស្តទឹកវិញកំពុងស្រោចហើយ ធ្វើរបងជុំវិញសួន ធ្វើរួចហើយ ដាំស្ពៃគ្រប់មុខ ដាំបានស្ពៃស្ពៃឆេសុីម (ស្ពៃចង្កឹស) និង ស្ពៃក្តោប។
- **គឹម ណា (ស):** ផែនការមាន៣ ដាំស្ពៃចង្កឹស និងស្ពៃខៀវ ដាំរួចហើយបានលក់ទៀត ធ្វើទ្រុងមាន់រួចចិញ្ចឹមត្រីរួចហើយ។
- **សាំង សារី (ប):** ធ្វើទ្រុងមាន់រួច ធ្វើជីអុីអឹមរួច ។

តើបុគ្គលិក លោក **ប៉ុល សុីនួន** បានចុះទៅតាមដានឬទេ? **សុីនួន** មិនបានទៅទេ តែមានបុគ្គលិកខាងផ្នែកកសិកម្មជាអ្នកទៅជំនួសវិញ។

**KIPD**

- **ស៊ឹម ទុង (ប):** រៀបចំសួនដាំបន្លែ ដាំត្រប់ ម្ទេស ត្រកួន សណ្តែក ត្រសក់ បានគាស់ដីរួចស្រេចហើយ បានសាបកូនតែមិនទាន់បានដាំទេ។
- **ប៉ាល់ យឿន (ប):** មានផែនការ២ រៀបចំធ្វើរបង មិនទាន់បានធ្វើទេទើបតែបានត្រួសត្រាយ រៀបចំដីធ្វើផ្ទះ ទើបតែបានត្រួសត្រាយដែរ មិនទាន់បានសំរេចទាំងអស់ទេ។
- **វិរហុង (ប):** ផែនការមាន២ គាស់កាយដីថ្មី និង ធ្វើរបង ទើបតែបានត្រួសត្រាយដីទេ ដល់ខែ៩ បានធ្វើបន្ត។
- **ផេត (ស) :** ផែនការមាន៤ ធ្វើសួនបន្លែ ធ្វើរួមហើយ ដាំត្រប់ ត្រកួន ស្ពៃ ដាំបានតែននោង ដាំស្វាយមិនទាន់បានដាំទេ ធ្វើរោងជី ធ្វើរួចហើយ។

តើលោក **ណម ៣** បានចុះទៅមើលសកម្មភាពរបស់កសិករ ឬទេ? បានទៅ តែភូមិខ្លះមិនបានទៅទេ ព្រោះទឹកលិចតែបានទាក់ទងតាមទូរសព្ទ័។

**KAFDOC**

- **សុី នីន (ស):** ផែនការមាន៣ រៀបចំធ្វើអាងបណ្តុះផ្សិត មិនទាន់បានរៀបចំទេ ព្រោះរកទិញអាចម៍រណាកៅស៊ូមិនទាន់បាន ធ្វើទ្រុងមាន់មិនទាន់បានធ្វើទេ ព្រោះទឹកលិចដាំបន្លែ បានបណ្តុះពូជហើយ។
- **អុិ ទី (ប):** ផែនការមាន៣ ជួសជុលទ្រុងមាន់ និងសួនបន្លែ បានជួសជុលទ្រុងមាន់ កន្លែងដាំបន្លែទឹកលិចរោងបណ្តុះផ្សិតកំពុង ទំនាក់ទំនងជាមួយជនបង្គោលធ្វើរោងបណ្តុះផ្សិត។

- **ស្វង សុភាព (ប):** ធ្វើរោងបណ្ដុះផ្សិត បានរៀបចំរោងហើយតែមិនទាន់បានមេផ្សិត ធ្វើទ្រុងមាន់មិនទាន់បានធ្វើទេ រៀបចំថ្នាលចិញ្ចឹមជន្លេន មិនទាន់បានធ្វើទេ ដាំបន្លែក៏មិនទាន់បានដាំដែរ ព្រោះទឹកលិច។
- **អ៊ីន (ប):** ស្លៃចង្កឹស ស្លៃក្រញាញ់ ត្រសក់មិនទាន់បានដាំទេ ទឹកលិច រោងជីកំប៉ុស្តធ្វើរួចហើយធ្វើនៅលើដីទួល។

ខេត្តក្រចេះមានវិបត្តិធ្ងន់ធ្ងរខាងទឹកជំនន់ ពិបាកក្នុងការចុះតាមដាន និងបញ្ចុះបញ្ចូលណាស់ ព្រោះគិតពីបញ្ហាក្រពះសិន គាត់រវល់ទៅរកចំណូលដើម្បីបំពេញក្រពះ ពិបាកក្នុងការដាំដុះ ចិញ្ចឹម។ ហើយសព្វថ្ងៃគំរោងគ្រោះមហន្តរាយខាងអាក់សិនអេតក៏កំពុងធ្វើការមមារញឹកដែរ ព្រោះវាធ្វើឱ្យប៉ះពាល់ដល់សុខភាពមនុស្ស សត្វ។

**CWDCC**

- **ង៉ែត សុផន (ស):** ដាំដំលូងជ្វា មិនទាន់បានដាំទេរវល់ស្ទូង ទិញមាន់បន្ថែមមិនទាន់បានទិញទេ ព្រោះកំពុងខ្វះខាតថវិកា។
- **ឈិត ហួរ (ប):** ដាំស្លៃចង្កឹស មិនទាន់បានដាំទេ ត្រលប់មកធ្វើស្រែវិញ ដាំត្រកួនមិនទាន់បានដាំទេ ធ្វើទ្រុងជ្រូកមិនទាន់បានធ្វើទេ។
- **ស្រី មួយ (ស):** ដាំបន្លែ មិនទាន់បានដាំទេ ចិញ្ចឹមមាន់បានធ្វើហើយ។
- **កែវ គង់នៅ (ប):** ដាំល្ពៅបានដាំហើយ ប៉េងប៉ោះដាំរួចហើយ ដាំម្ទេសរួចហើយ ដាំត្រលាចដាំរួចហើយ។ ដំណាំទាំងអស់នេះជាដំនាំដែលជួបបញ្ហានៅរដូវខែ០៨-០៩ នេះ ។ <u>ចាប់ពីខែ០៥-១០ ឬ១១ មានកូនរដូវប្រាំងមួយនៅក្នុងនោះគឺ ចុងខែ០៧ និងដើមខែ០៨។</u>

ចំពោះវិបត្តិថ្នាំពុលតើយ៉ាងម៉េចហើយ? គេបានធ្វើការសិក្សាស្រាវជ្រាវហើយ តែមិនឃើញមានសំណង មិនឃើញ មានការតវ៉ាអ្វីទាំងអស់? តាមរយៈការបកស្រាយតាមទូរទស្សន៍ ឃើញថាគេចោទថាពួកគាត់ដើរចូលព្រៃ ខ្យល់គរដោយខ្លួនឯង។

**KDDF**

- **អាន រ៉ម (ស):** ដាំបន្លែ មិនទាន់បានដាំទេ ធ្វើរណ្ដៅអាចម៍គោមិនទាន់បានធ្វើទេ ធ្វើទ្រុងមាន់មិនទាន់បានធ្វើដែរ។
- **អ៊ុំ ធំ (ប):** ចិញ្ចឹមត្រីមិនទាន់បានធ្វើទេ ប៉េងប៉ោះមិនទាន់បានធ្វើ ស្លៃសាបកូនហើយ ដាំត្រសក់មិនទាន់បានធ្វើ។
- **សឿង រិទ្ធី (ប):** ទិញពូជមាន់ទិញរួចហើយ ទិញពូជត្រី ទិញរួចហើយ ដាំខាត់ណាផ្កា បានសាបកូនហើយ។
- **ឡុង ជ្រាប (ស):** ទិញពូជត្រីមិនទាន់បានទិញទេ ធ្វើទ្រុងជ្រូក បានរៀបចំឈើ និងស៊ីម៉ង់។

តើកសិករខាងខេត្តកំពង់ស្ពឺ **លោក ស្នា** មានចុះតាមដានឬទេ? បានខ្លះតែមិនសូវញឹកញាប់ទេ សូមកសិករជួយធ្វើឱ្យបានជោគជ័យ ព្រោះគាត់មិនសូវជារឹងមាំដូចយើងនោះទេ តែគាត់ខិតខំប្រឹងប្រែងណាស់ក្នុងការដឹកនាំកសិករ។

សរុបមកកម្មភាពដែលបានដាក់ធ្វើមិនទាន់បានសំរេចទេ តែគាត់ចេះបត់បែនមកធ្វើសកម្មភាពផ្សេងទៀតដូចជា : ស្ទូងស្រូវជាដើម។ តើយើងទាំងអស់គ្នាបានជួបវិបត្តិសេដ្ឋកិច្ច ឬទេ ដូចជា: ខ្វះចំណូល ខ្វះស្បៀង ត្រូវស៊ីឈ្នួលគេ តើមានអ្នកណាខ្វះខាតខ្លះ?

សួរបែបនេះដើម្បីចង់ដឹងថាផែនការដែលបានដាក់គឺត្រូវតែធ្វើ តែមិនឱ្យបងប្អូនប្រឹងធ្វើដោយខ្លួនឯងកំពុងតែខ្វះស្បៀងនោះទេ ត្រូវចេះបត់បែន ឆ្លៀតឱកាសធ្វើអ្វីផ្សេងសិន ដើម្បីបំពេញក្រពះសិន យើងត្រូវចេះច្នៃប្រឌិត។ ផែនការដែលនៅសល់នឹងធ្វើបន្តទៀត នៅថ្ងៃទី៤ ហើយយើងនឹងធ្វើការតាមដានបន្តទៀតដែរ។

ល្បែងស្ទាងអារម្មណ៍ របស់**អ្នកស្រី ស៊ិន ស៊ីណេះ:** ល្បែងថើបគ្នា ដោយឱ្យសិក្ខាកាមឈរជារង្វង់ ហើយឱ្យម្នាក់រត់ទៅថើប ដោយធ្វើមាត់ស្រួច រត់ទៅរកគេ ហើយអ្នកត្រូវរត់គេច ហាមបុរស រត់រកបុរស:




ជាកិច្ចបន្ត លោក **អូត ឡុង** បានសម្របសម្រួលពីបច្ចេកទេសនៃការធ្វើជីធម្មជាតិ:

**១ – <u>របៀបធ្វើមេជីអ៊ីអឹម ធម្មជាតិ:</u>**

- <u>ធាតុផ្សំ:</u>
  - ដីដំបូកបុកម៉ដ្ឋ១ គីឡូក្រាម
  - កន្ទក់ម៉ត់ ១ គីឡូក្រាម
  - ស្ករត្នោតធម្មជាតិ ១.៣ គីឡូ
  - ទឹកច្រោះស្អាតធម្មតា ឬទឹកសុទ្ធ ១លីត្រ
  - ក្រណាត់សរទេសឯក ១ ម៉ែត្រ ៤ជ្រុង ឬ ក្រម៉ាអំបោះឆៅ
  - ធុងទឹកចំណុះ ២៥លីត្រ មានគំរប
- <u>របៀបធ្វើ:</u>
  - យកកន្ទក់លាយជាមួយដីដំបូកឱ្យសព្វ ហើយយកស្ករ៣ខាំមកលាយជាមួយទឹកឱ្យរលាយអស់រួចយកមកស្រោចពីលើកន្ទក់ និងដីដំបូកដែលច្របល់រួចម្តងបន្តិចៗទាល់តែសព្វអស់ទឹក១លីត្រ ហើយយកដៃប្របាច់ក្នុងកណ្តាប់ដៃហើយណែនបើហូរទឹកតាមដៃនោះត្រូវហើយ បើមិនទាន់ហូរទឹកទេត្រូវស្រោចទឹក នោះបន្ថែមទៀត មិនឱ្យលើសមួយលីត្រទេ។

- បន្ទាប់មកយកក្រណាត់មកគ្របកន្ទក់ដែលយើងបានលាយចងឱ្យជិត ហើយសង្កត់ជុំវិញម្តងម្ខាងៗគ្រប់ជ្រុង ហើយរក្សាទុកឱ្យស្អាត គ្របឱ្យជិតមិនឱ្យមានស្រមោច រោម រុយរោម បានទេ ព្រោះវាអាចនឹងធ្វើឱ្យខូចមេជី ហើយដាក់ពីលើចាន ហើយដាក់ថាពីខាងក្រោម១ជាន់ទៀត ដោយដាក់ទឹកពីលើថាសចៀសវាងស្រមោចឡើង។ គ្របទុករយៈពេល ៣-៤ ថ្ងៃ ធ្វើយ៉ាងណាឱ្យមានខ្យល់ចេញចូលគ្រប់គ្រាន់ ២ថ្ងៃត្រលប់ម្តងដាក់ម្ខាងទៀត ឬអាចចងបណ្តោងក្នុងទ្រុងសំណាញ់ក៏បានដែរ តែត្រូវលាបប្រេងកុំឱ្យស្រមោចឡើងរោមមេជី។ **ហាមដាក់ទឹកទាំងអស់ តែម្តងប្រសិនបើមិនទាន់បាន ច្របាច់មើលសិន។**
- ពេលគ្រប់កាលកំណត់ហើយ យកស្ករត្នោតនៅសល់១គីឡូ នោះទៅកំទ្បោចឱ្យក្លាយជាតាំងម៉ែចាស់ ដោយសាកល្បងពីដួសទឹកចេញពីទឹកនឹងត្រៀមចាក់ស្ករបញ្ចូលនោះ (ទឹក២០លីត្រ) យកស្ករមកបន្តក់ក្នុងទឹកហើយយកមកកាច់ បើស្រួយនោះត្រូវហើយ ហើយយកទឹកដែលនៅសល់នោះចាក់ចូលក្នុងឆ្នាំងខ្ទះកុំឱ្យខ្លោចទាន់។ កាលណាស្ករមិន កើតនោះអ៊ីអឹមក៏ធ្វើមិនកើតដែរ។ ក្រោយពីចាក់រួចហើយមកត្រូវទុកឱ្យត្រជាក់សិន ទើបដាក់មេដែលរក្សាទុកនោះចូលទៅក្នុងទឹកដោយច្របាច់ឱ្យបែក ហើយគ្របទុករយៈពេល ២២ ថ្ងៃ ទុកដាក់ក្នុងម្លប់ឱ្យស្អាត អាចប្រើបាន។ ត្រូវកត់ថ្ងៃដែលយើងដាក់ឱ្យបានត្រឹមត្រូវនៅលើគំរបហើយធ្វើការតាមដាន។

- <u>របៀបប្រើប្រាស់ និង សារៈប្រយោជន៍:</u>
  - មេជី១លីត្រលាយទឹកធម្មតា ៥០០លីត្រ សំរាប់ដាំដំណាំហូបស្លឹក បាញ់ស្រោចពីលើស្លឹក ដោយមិនចាំបាច់ចាក់ទឹកបន្សាបនោ,ះទេ យកល្អស្រោចពេលល្ងាច អាចស្រោចពី៥-៧ ថ្ងៃម្តង ឬរាល់ថ្ងៃតាមលទ្ធភាព។
  - មេជី១លីត្រ លាយជាមួយទឹកធម្មតា ១០០លីត្រ សំរាប់បាញ់សំលាប់មេរោគក្នុងដី។
  - មេជី១លីត្រ លាយជាមួយទឹកធម្មតា ១០០លីត្រ សំរាប់ពេលស្រូវធ្វើខ្លួន និង ពេលស្ទូងរួចរយៈពេល១៥ថៃ។
  - មេជី១ភាគ៤លីត្រចកគោ ក្របី ឈឺ គ្រុន មិនចង់ស៊ីស្មៅ បះរោម រាគមួល អាចច្រកបាន ក្នុង១ថ្ងៃច្រកម្តង។ ហាមយកទៅច្រកគោ ក្របី សារខ្យល់ សារទឹក អុតក្តាម មិនអាចជាបានទេព្រោះវាមិនមែនជាថ្នាំព្យាបាលទេ
  - មេជី១គំរបដបទឹកសុទ្ធលាយជាមួយទឹកដាក់ឱ្យមាន់ផឹករៀងរាល់ថ្ងៃ។
  - មេជី១លីត្រលាយទឹក៥០លីត្រ និងទឹកខ្មេះ ១ភាគ២លីទ្រ លាងលើស្បែកជ្រូក គោ ក្របី និង មេជី១លីត្រលាយជាមួយទឹក២០លីត្រ សំរាប់ចាក់លើទ្រុងជ្រូកដើម្បីបំបាត់ក្លិនស្អុយ ។
  - មេជី១លីត្រលាយជាមួយទឹក១០-១៥ លីត្រ ធ្វើឱ្យកើតកណ្តៀរសំរាប់ចំណីមាន់។ ដោយជីករណ្តៅជំរៅ ២-៣តឹក ហើយប្រមូលយកសំរាមស្ងួតជុំវិញផ្ទះមកដាក់ក្នុងរណ្តៅឱ្យពេញ ហើយយកទឹកមកស្រោចច្របល់ឱ្យសព្វ ហើយគ្របឱ្យជិតការពារកុំមាន់កកាយ ផ្អាប់ទុករយៈពេល ៧ថ្ងៃអាចបើកឱ្យមាន់ស៊ីបានហើយ។ ពេលស៊ីអស់ហើយត្រូវថែមសំរាម និងជីទៀត ដើម្បីបង្កើតម្តងទៀត តែធ្វើបែបនេះ២-៣ដង អាចកើបយកមកធ្វើជីកំប៉ុស្តគោកបាន។ **មេជីនេះរក្សាទុកបាន១ឆ្នាំ ទៅ១ឆ្នាំកន្លះ។**

- ប្រសិនបើវាខូចយើងអាចយកទៅស្រោចលើដើមមាន ក្រូចឆ្មារ ត្រកួន ស្វាយ....ក៏បានដែរ។

លោកស្រី **ស៊ិន ស៊ីណន** ចំពោះការថ្លឹង ត្រូវថ្លឹងជញ្ជីងតែមួយ ហើយស្តុកកុំទិញមកទុកទិញតែ៣ខាំមកសិនទៅ កាលទិញទាំងអស់យើងទុកទៅ អាចច្រលំយកមកស្ល ឬក្មេងយក។

ល្បែងស្វាងអារម្មណ៍ៈ ល្បែងទស្សន៍ទាយសកម្មភាព ដោយចែកគ្នាជា២ក្រុម ហើយមានមនុស្ស៥នាក់ជាអ្នកធ្វើសកម្មភាពឱ្យក្រុមធំជាអ្នកទាយ។ សម្របសម្រួលដោយ**អ្នកស្រី ស៊ិន ស៊ីណន។**

២- **<u>របៀបធ្វើជីកំប៉ុស្តគោកៈ</u>** កាត់បន្ថយថវិកាទិញជីពីទីផ្សារ មានសុខភាពល្អ ជួយកែប្រែគុណភាពដី.....។ ការធ្វើជីនេះភាគច្រើនធ្វើនៅខែវស្សាព្រោះវាសំបូរទៅដោយធនធាន។

- <u>ធាតុផ្សំៈ</u>
  - លាមកសត្វ អង្កាមដុត ឬឆៅ ចំបើង ទន្រ្ទានខេត្ត ផេះ ដីដំបូក ឬដីបាតបឹង សំរាមស្ងួតជុំវិញផ្ទះ ស្លឹករុក្ខជាតិផ្សេងៗទៀត ដែលឆាប់រលួយដូចជាៈ កំប្លោក ស្លឹកដំលូងមី ស្លឹកបន្លែផ្សេងៗ អង្កាញ់.. បានច្រើនកាលណាកាន់តែល្អ។ ដីដំបូក និង លាមកសត្វ ចំនួនស្មើរគ្នា។ តែចំពោះលាមកមាន់ ឬ ប្រចៀវបើមានគួរតែទុកសំរាប់ដាំខ្ទឹមវិញ ព្រោះវាល្អជាងជីកំប៉ុស្តទៀត អាចយកតែលាមកគោ ក្របីមកបានហើយ។
  - ទឹកសំរាប់ស្រោច។ ចំពោះវត្ថុធាតុផ្សំទាំងអស់មិនកំណត់ថាអាចមានគ្រប់ទាំងអស់នោះទេ។
- <u>របៀបធ្វើៈ</u>
  - ចិញ្រ្ចាំវត្ថុទាំងនោះឱ្យល្អិត ហើយលាយបញ្ចូលគ្នាឱ្យសព្វ រួចហើយយកទឹកមកស្រោចពីលើឱ្យសើមសព្វ រួចគ្របឱ្យជិតនៅក្រោមម្លប់ទុករយៈពេល២០ថ្ងៃអាចប្រើបាន (ត្រូវសំដិនឱ្យស្ងួតហើយអាចច្រកទុកដាក់ក្នុងការ៉ុងទុកប្រើបាន។ បញ្ជាក់ រយៈពេល១០ថ្ងៃត្រូវបើកមើលហើយស្រោចទឹកម្តងទៀត ព្រោះធាតុផ្សំនៅខាងក្រៅមិនទាន់រលួយទេ (មិនមានកំដៅ)។ ការធ្វើជីត្រូវធ្វើបន្ត ឬធ្វើទុកសំរាប់ប្រើប្រាស់។
- <u>របៀបប្រើប្រាស់ៈ</u> ជីនេះប្រើសំរាប់ទ្រាប់បាត។
  - ចំពោះដីខ្សាច់ ដីខ្វះជីជាតិ ដីឈើ ១ម៉ែត្រការេ ៣-៤ គីឡូ ចំពោះដំណាំបន្លែទូរទៅ ។

៣- **<u>របៀបធ្វើជីកំប៉ុស្តទឹកៈ</u>** ចំពោះបន្លែដែលប្រើជីនេះមានស្លឹកក្រាស់ ហើយមានពណ៌បៃតងចាស់ ហើយមាលំអងទៀត។

- <u>ធាតុផ្សំៈ</u>
  - ស្លឹកម្រុំ ស្លឹកស្ពៃ ស្លឹកត្រកួន ស្លឹកទន្រ្ទានខេត្រ ស្លឹកកន្ទ្រោក ស្លឹកបាស់ ស្លឹកងុប ស្លឹកសណ្តែកខ្មោចមួយមុខ១គីឡូ ស្ករក្រហម ១គីឡូ ទឹក១០លីត្រ ឬទឹកនោមគោ ក្របីខ្លាំងជាងធ្វើជាមួយទឹកទៀត ស្បៃឈិប ១ដុំ=១ម៉ែត្រ។

- <u>របៀបធ្វើ:</u>
  - ចិញ្ច្រាំធនធានទាំងនោះហើយច្របល់ឱ្យសព្វ ហើយយកទឹក១០លីត្រលាយជាមួយស្ករត្នោត ចាក់ចូលទៅក្នុងពាង ឬធុង ហើយយកស្លឹករុក្ខជាតិទាំងនោះមកចងក្នុងស្បៃហើយដាក់បញ្ចូលទៅក្នុងទឹកនោះ គ្របឱ្យជិត១ថ្ងៃបើកកូរម្តង ដើម្បីឱ្យវាកាច់។
- <u>របៀបប្រើប្រាស់:</u>
  - យកមេជី១លីត្រ លាយជាមួយទឹកធម្មតា ១០០លីត្រ ឬមួយធុងលាយជាមួយមេជីមួយគំរបដបទឹកសុទ្ធ។
- <u>អត្ថប្រយោជន៍:</u>
  - បន្លែលូតលាស់លឿន ហើយមានរសជាតិផ្អែម។

**<u>ការធ្វើមេជីទឹកម្យ៉ាងទៀត:</u>**

១ – <u>វត្ថុធាតុផ្សំ:</u> ខ្យង ក្តាម ត្រី កំពឹស សរុបទាំងអស់ យក១០គីឡូ ប្រើស្ករត្នោត២–៣គីឡូ ទឹក៣០–៤០លីត្រ និងអំបិលកន្លះគីឡូ ផ្អាប់ទុក២៥–៣០ថ្ងៃ។ តែបើដាក់ទឹកនោមគោ ក្របី ចំនួន ២៥–៣០លីត្រ បានហើយផ្អាប់ទុក ១៥–២០ថ្ងៃអាចប្រើបាន។ អាចទុករយៈពេល ១០០ថ្ងៃ ហើយបន្ថែមធនធានបន្តបន្ទាប់។

២– <u>វិធីប្រើ:</u> មេជី១លីត្រ លាយជាមួយទឹកធម្មតា ៤០០–៥០០លីត្រ ស្រោចលើដំណាំ ហើយពេលព្រឹកត្រូវលាងចេញវិញ ព្រោះវាខាំងអាចធ្វើឱ្យរលួយ ឬប្រេះបាន។

៣ – **<u>បញ្ជាក់:</u>** លាមកមាន់មិនអាចដាក់ផ្ទាល់នៅគល់ត្រឡាច ល្ពៅ ននោងបានទេ។

**៤– <u>ថ្នាំបណ្តេញសត្វល្អិត:</u>** ជាថ្នាំបណ្តេញសត្វទេ មិនមែនសំលាប់ទេ តែបើយើងប្រើច្រើនពេកធ្វើឱ្យស្លាប់សត្វមានប្រយោជន៍ ហើយសត្វបំផ្លាញនឹងកើនឡើង។ **<u>ថ្នាំពុលមាន៣យ៉ាង:</u>** ពុលពេលបើកគំរបពាងចេញ ពុលពេលលាយថ្នាំ ពុលពេលដើរបាញ់ តាមរយៈរន្ធញើស ឬរន្ធធម្មជាតិ ព្រោះថ្នាំពុលចូលហើយមិនមានចេញមកវិញទេ យើងត្រូវការពារនៅពេលប្រើថ្នាំ។

- <u>ធាតុផ្សំ:</u>
  - រុក្ខជាតិណាដែលមានជាពុល កំពុល ហិល ល្វីង មួយមុខ១គីឡូ (១០គីឡូ=១០លីត្រ)
- <u>របៀបធ្វើ:</u>
  - ចិញ្ច្រាំវត្ថុធាតុផ្សំទាំងនោះបញ្ចូលគ្នា ហើយដាក់ចូលទៅក្នុងទឹក១០លីត្រ ហើយគ្របឱ្យជិតទុករយៈពេល ២០ថ្ងៃ អាចប្រើបានហើយ
- <u>របៀបប្រើប្រាស់:</u>

- ទឹកថ្នាំ១ លីត្រលាយជាមួយទឹក ១៥–២០ លីត្រ
- សត្វក្បាលីរ៉ងមកស៊ី មេជី១ លីត្រ លាយជាមួយទឹក១៥លីត្រ ហើយថែមសាប៊ូម្សៅ និងថ្នាំខ្លាំងបន្តិច។
- ចៀសវាងការបាញ់នៅពេលព្រឹក (មិនទាន់អស់ទឹកសន្សើម) និងពេលថ្ងៃក្តៅខ្លាំង (ព្រោះវាក្តៅ) ធ្វើឱ្យដំណាំហាក់ណាស់ ពេលដែលល្អបាញ់នៅពេលល្ងាច ព្រោះសត្វហើរចេញអស់ហើយ។
- ចំពោះដំណាំស្រូវ១ ហិចតា ត្រូវបាញ់ប៉ុន្មាន? យើងបាញ់តែកន្លែងដែលមានសត្វស៊ីបានហើយ ព្រោះយើងមិនអាចធ្វើបានច្រើនទេ។ **កណ្តុរស៊ីស្រូវច្រើន និងខ្លាំងជាងគេនៅពេលស្រូវភើម។ កណ្តុរមេ១ ឈ្មោល១ ១ឆ្នាំបង្កើតកូនបាន ២៤០០ក្បាល។** កណ្តុរស៊ីស្រូវធ្វើយ៉ាងណា? ១–ចាប់កណ្តុរដេរគូថ នោះវាខាំគ្នាពេញនោះហើយ។
- <u>**បញ្ជាក់:**</u> ត្រូវរក្សាទុកឱ្យបានល្អកុំឱ្យកូនយកបាន ការពារសត្វផងដែរ ប្រយ័ត្នមានគ្រោះថ្នាក់។

## ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១១

ល្បែងស្វាងអារម្មណ៍ **ល្បែងដំលូងក្តៅ:** ឱ្យសិក្ខាកាមឈរជារង្វង់ហើយបោះដុំដំលូងតគ្នាពីម្នាក់ទៅម្នាក់ ដោយចាក់ចំរៀង ប្រសិនបើចំរៀងចប់នៅអ្នកណាអ្នកនោះត្រូវបកមួយសន្លឹកទុកនឹងខ្លួនសិនរហូតដល់អស់ក្រដាស។ បន្ទាប់មកឱ្យអ្នកចូលរួមអានសារដែលខ្លួនទទួលបានមានទាំងការធ្វើការវិការ ការឆ្លើយសំណួរទាក់ទងនឹងមេរៀន ហើយធ្វើតាម និងឆ្លើយនឹងសំណួរ។

- ធ្វើកង្កែបលោត
- យំគោក
- វត្ថុធាតុផ្សំថ្នាំបណ្តេញសត្វល្អិតមានអ្វីខ្លះ?
- របៀនៃការធ្វើជីកំប៉ុស្តគោក ទឹក?
- ការប្រើប្រាស់ថ្នាំបណ្តេញសត្វល្អិត?

<u>**សំណួរសិក្ខាកាម:**</u>

១ – ធ្វើមេជីអ៊ីអឹម ធ្វើយ៉ាងម៉េចដឹងថាខូច(មានជាតិជូរ)? ធ្វើយ៉ាងម៉េចដឹងថាល្អ(ដុះផ្សិតពណ៌សរ)?

២– តើជីអ៊ីអឹមប្រើបានដំណាំអ្វីខ្លះ? ប្រើបានគ្រប់ប្រភេទ តែមានរបៀបនៃការប្រើទៅតាមប្រភេទដំនាំនីមួយៗ។

ការបង្ហាញពីសួនពហុប្រយោជន៍របស់ **លោក សុខ វឿន :**

- សួនពហុប្រយោជន៍ គឺរុក្ខជាតិ បន្លែ សត្វ ណាដែលមានប្រយោជន៍ចាប់ពី២មុខឡើងទៅ។
- <u>**ស៤:**</u> ស្រះ ស្រែស្រូវ សួន សត្វ។

**កញ្ញា សេន គឹមថេង:**

- តើក្នុងចំណោមយើងទាំងអស់គ្នាមានប៉ុន្មាននាក់ដែលមានសួនបន្លែ?
  - O **ក្នុងចំណោម ២៧នាក់ អ្នកមានសួនដំនាំគ្រួសារមាន ១០គ្រួសារ ដែលមានដាំដូចជា:** ស្ពៃ សណ្តែក ត្រកួន ត្រសក់ ត្រលាច ឪឡឹក ល្ពៅ ម្ទេស ត្រាវ សាលាដ ស្លឹកគ្រៃ ជីគ្រប់មុខ ននោង ខ្ទឹម ខ្ទាយ រមៀត រំដេង ... ។
  - O ១៧នាក់ ទិញពីទីផ្សារ ១ឆ្នាំពេញ។
- ក្នុងចំណោះ១០គ្រួសារដែលមានសួន បន្លែមានប៉ុន្មាននាក់ដែលមិនទិញបន្លែពីទីផ្សារ?
  - O មាន១ គ្រួសារដែលមិនទិញ ពីទីផ្សាររយៈពេល ១ឆ្នាំ តែចំពោះសាច់គោ ត្រី គឺទិញ។
  - O ហើយក្នុងនោះមាន ៧គ្រួសារទិញបន្លែនាំចូលពីទីផ្សារ។
  - O ៣ នាក់ទិញគេចំនួន ២-៣ ខែ។
  - O ១ខែកសិករអាចសល់ ៦០០០០រៀល ពីការទិញបន្លែ ប្រសិនបើយើងអាចដាំខ្លួនឯងបាន។

**<u>របៀបរៀបចំដីសួនពហុប្រយោជន៍:</u>**

- មានស្រះទឹកចិញ្ចឹមត្រី មានប្រភពទឹក
- មានសួនបន្លែ
- មានទ្រុងជ្រូក មានទ្រុងមាន់
- មានដើមឈើពហុប្រយោជន៍
- ចេះរៀបចំដី ដីនៅវាលស្រែ ដាំដើមឈើដែលមានប្រយោជន៍ច្រើនមុខ និងដំនាំយុទ្ធសាស្ត្រ
- ការរៀបចំដី សំរាប់ដាំបន្លែកាប់ដីហាលរយៈពេល ៧-១០ថ្ងៃ នៅរដូវវស្សា នៅរដូវប្រាំងហាល៤-៧ថ្ងៃដើម្បីសំលាប់មេរោគក្នុងដី
- ក្រោយពីធ្វើដីរួចធ្វើថ្នាល បណ្តុះកូន ផ្ទេរងដាំកូន បន្លែហូបស្លឹក ហូបផ្លែ ត្រៀមដីសំរាប់ដាំដំនាំរិលជុំ រៀបចំដីសំរាប់ដាំដំណាំយុទ្ធសាស្ត្ររយៈពេលវែង។

**<u>របៀបថែរក្សា និងទុកដាក់ពូជ:</u>**

- បេះទុកលាងឱ្យស្អាត ហាលទាំងយប់ទាំងថ្ងៃរយៈពេល៧ថ្ងៃ វេចខ្ចប់ទុកក្នុងស្បៃឱ្យបានល្អ ដើម្បីកុំស្រមោច ឬសត្វស៊ី។
- ដំណាំត្រលាច ដាំនៅខែ ៣-៤ ទទួលបានផលល្អ មិនរើសតំបន់ទេ តែបើដាំខែ ៥-៦ សំបូរស្លឹកមិនសូវសំបូរផ្លែទេ។
- ចំពោះពូជដែលទិញពីទីផ្សារគឺគេប្រើថ្នាំ ហើយបើយើងទិញមកប្រើ ទាល់តែ៣ឆ្នាំទើបបានផុតជាតិថ្នាំនោះ។
- ចៀសវាងការទុកក្នុងថង់ ក្នុងដបឱ្យសោះ ត្រូវដាក់នឹងស្បៃរុំ។
- ការទុកពូជគឺទុកផ្លែទី១ និងផ្លែទី២ តែបើផ្លែមិនល្អយើងក៏មិនយកដែរ។

- ត្រលាច ននោង ឃ្លោក ម្រះ ទុកបាន២ប្រភេទ: ១–ទុកផ្លែទាំងមូល ២–ពុះជា២យកផ្លែមកលាងទឹកឱ្យស្អាតចាំហាលថ្ងៃចាប់ ពីម៉ោង៨–៩ (១៥នាទី)ជារៀងរាល់ថ្ងៃ ២–៣ថ្ងៃ បន្ទាប់មកខ្ចប់ទុក។
- ការបេះត្រូវប្រើដោយកំបិត ឬកន្ត្រៃ ហាមប្រើដោយដៃវាធ្វើឱ្យប៉ះពាល់ដល់ផ្លែផ្សេងៗ ត្រូវបេះដោយថ្នមៗ។
- គ្រាប់ពូជផ្សារមានឥទ្ធិពលខ្លាំងផ្លែធំៗតែបានតែ២–៣សារទេ តែបើពូជទុកខ្លួនឯង បាន ៧–៨សារ។
- ធ្វើឱ្យត្រូវទាំងអស់ព្រោះយើងជាកសិករគំរូទាំងពីការបេះ ការទុកពូជ ការដាំ ការធ្វើជី...។
- **ការទុកពូជស្រូវ:** ប្រើកន្ទេលសំរាប់ហាល ឬស្បៃ បើមានថ្ងៃរះត្រូវចាប់ផ្តើមហាល បើស្រទុំកុំហាល ការហាលគឺចាប់ពីម៉ោង ៨–១១ ពីម៉ោង ១១:៣០–១២:៣០ ត្រូវប្រមូលស្រូវគ្របទុកមួយអន្លើសិន ហួសម៉ោងនោះចាំបកហាលបន្តទៀត ម៉ោង៥ សារទុក។ បើមិនដូចនេះទេវានឹងងាប់សារជាតិលូតលាស់របស់វាហើយ។ ហាលរយៈពេល២ថ្ងៃច្រកទុកក្នុងម្លប់ ហើយយកកៅស៊ូ មករុំទុកឱ្យជិត នោះវានឹងដុះបានល្អនៅពេលដល់រដូវធ្វើស្រែទៀត។
- **ការដាំបន្ទោសៈ ដី និង ដៃ។** មិនមែនមកពីដៃ ឬដីទេ មកពីមិនដាក់ជី ស្រោចទឹក និង ថែទាំ។

**ល្បែងស្វាងអារម្មណ៍** ជ្រើសរើសសិក្ខាកាម៥នាក់ ៤នាក់ត្រូវបានចងភ្នែកជិតឱ្យ ហើយកាន់ខ្សែចំនួន៤ជ្រុង ដែលចងជាប់ដោយកៅស៊ូចំនួន១ នៅកណ្តាលខ្សែ ហើយ១នាក់ទៀតជាអ្នកបញ្ជា ឬដឹកនាំឱ្យអ្នកទាំង៤នោះធ្វើយ៉ាងណាអាចយកដបទឹក សុទ្ធចូលក្នុងកៅស៊ូ ហើយលើកយកទៅដាក់ម្ខាងទៀត។



- មិនបានសសំរេចទេ
- ពិបាកក្នុងការប្រាប់ណាស់អ្នកដឹកនាំក៏ពិបាក
  អ្នកធ្វើក៏ពិបាកព្រោះគាត់ងងឹត
- ត្រូវស្តាប់តែម្នាក់ កាលណាមានការណែនាំច្រើនធ្វើឱ្យមានការច្របូកច្របល់
- ការប្រាប់ ឬណែនាំមិនច្បាស់លាស់ ព្រោះគាត់ងងឹត គាត់មើលមិនឃើញទេ សារយើងត្រូវតែច្បាស់
- ការធ្វើអ្វីមួយត្រូវតែមានផែនការជាក់លាក់ ព្រោះអ្នកដឹកនាំមានតែម្នាក់ តែអ្នកក្រោមបង្គាប់មានច្រើនណាស់ ហើយគាត់មិនចេះទៀត

- **តើកសិករមានតួនាទីធ្វើអ្វីខ្លះ?**
  - O មានគំនិតច្នៃប្រឌិត
  - O មានបច្ចេកទេស
  - O មានយុទ្ធសាស្ត្រ

O អនុវត្តផ្ទាល់

O សម្របសម្រួល

O ផ្សព្វផ្សាយ

O ដឹកនាំ

O **ជាអ្នកគំរូគេ**







**ការវិភាគពីរដូវកាលនៃការដាំដុះ:**




**នៅពេលរដូវជាំទឹកតើយើងដាំយ៉ាងម៉េច?**

- ដាំលើកជារង
- ដាំនៅលើរាន
- លើកពូនដីឱ្យខ្ពស់

**នៅពេលសត្វល្អិតស៊ីតើយើងដោះស្រាយយ៉ាងម៉េច?**

- យកស្លឹកស្តៅបុកឱ្យម៉ដ្ឋ លាយជាមួយទឹកមួយផ្តិល ហើយយកមកលាយជាមួយទឹកធម្មតា១ធុង ស្រោចតែម្តង។

**១ – ដំណាំឆ្លាស់ជាមួយដំណាំ**

- ដាំត្រប់លាយជាមួយពោត : (ដំណាំត្រប់រយៈពេល៤៥ថ្ងៃទទួលផល តែបើបំប៉នជីធម្មជាតិជិតដល់តែ៣៨ថ្ងៃបានផល ពោតមាន២ប្រភេទ: ពោតស្រាលចាប់ផ្តើមដាំខែ១២ ពោតធ្ងន់ ៧២ថ្ងៃបានផល) ពេលប្រមូលផលពោតអស់កាប់វាឱ្យខ្លីៗដាក់នៅចន្លោះគុម្ពត្រប់នោះបានគ្របគល់។ ខែជ្រោគទឹកហាមដើរជាន់គល់ដំណាំ នាំឱ្យខូច។ ចំពោះត្រប់នៅពេលវាជ្រោគទឹកកុំកាប់វាចោលទុកឱ្យស្ងួតដី កាត់ស្លឹក កាត់មែកចេញ បំប៉នជីម្តងទៀត នឹងបានផលម្តងទៀត។
- ដាំពោតលាយជាមួយល្ពៅ ត្រសក់ស្រូវ
- ដាំសាលាដលាយជាមួយស្លឹកខ្ទឹម

**២– ដាំណាំឆ្លាស់**

- ដាំត្រកួនពេលដកដូរដាំស្ពៃ
- ដាំស្ពៃពេលដកដូរដាំសាលាដ
- ដាំសាលាដពេលដកប្តូរដាំស្លឹកខ្ទឹម
- **កូនរដូវប្រាំង (ចុងខែ០៧ ដើមខែ០៨) ដាំដំនាំបានល្អ។**
- **សណ្តែកគួរ**ពេលសិប្បូរស្លឹកនៅខាងក្រោម ត្រូវកាត់ចេញខ្លះ នៅពេលប្រមូលផលអស់យើងអាចកាត់ចេញដើមវល្លិ៍ដែលឥតប្រយោជន៍ បំប៉នជីនោះនឹងទទួលផលម្តងទៀត។
- **ជីទឹកនោម:** យកទឹកនោមលាយជាមួយក្បាលត្រី អាចម៍ត្រី ទុករយៈពេល១៥ថ្ងៃអាចប្រើបាន។
- ដាំល្ហុងត្រូវដាំទ្រេត ដើម្បីឱ្យវាចាប់ឫសបានល្អ។
- ចំពោះផ្លែ ផ្លែអ្វីក៏ដោយឱ្យតែច្រើន ត្រូវតែកាត់ចោលផ្លែណាដែលមិនល្អហើយទុកតែផ្លែល្អ។

**ដូចម្តេចដែលហៅថាសួនពហុប្រយោជន៍?          សម្របសម្រួលដោយកញ្ញា សេន គឹមលេង:**

- <u>សួនពហុប្រយោជន៍គឺ</u> ជាសួនដែលមានប្រយោជន៍ច្រើន។ ក្នុងសួនមានគោលការណ៍៤: ស្រះ សត្វ សួន ស្រែស្រូវដែលចេញពីធម្មជាតិ (ប្រសិនបើយើងមានដីតូច មិនមានស្រែក៏បានដែរ)។ ហើយគោលការណ៍ទាំង៤នេះគឺនៅលើដីតែមួយ មិនមែនដី តែមួយជ្រុងណាមួយនៃដីដែលយើងមាននោះទេ។
  - ស្រះមានអ្វីខ្លះ? ធ្វើយ៉ាងម៉េច?
  - សួនមានអ្វីខ្លះ? ធ្វើយ៉ាងម៉េច?
  - ស្រែស្រូវមានអ្វីខ្លះ? ធ្វើយ៉ាងម៉េច?
  - សត្វមានអ្វីខ្លះ? ធ្វើយ៉ាងម៉េច?
    - គូរផែនទីជាក់ស្តែង និងផែនទីក្តីស្រម៉ៃហើយរក្សាទុកដើម្បីការតាមដាន និងប្រៀបធៀប។

- វិភាគពីធនធានផ្អែកលើផែនទីក្តីស្រម៉ៃ (គាត់ចង់ធ្វើអ្វីមុន ត្រូវការធនធានអ្វីខ្លះ បានមកពីណាខ្លះ ចំនួនប៉ុន្មាន? ដើម្បីធ្វើឱ្យក្លាយជាការពិត និងអាចក្លាយជាសួនបង្ហាញបាន) ប្រើសួនជាសាលាកសិកម្ម តាមដាន សង្កេត តាមរយៈការអនុវត្តជាក់ស្តែង។
- ធ្វើផែនការបន្តសំរាប់ ៣–៦ ខែ។
- សួនពហុប្រយោជន៍សំខាន់គឺរៀបចំដីកុំឱ្យលិចទឹកសិន ទើបរៀបចំបាន។

| ល.រ | សកម្មភាព | ពេលវេលា | ទីកន្លែង | អ្នកទទួលខុសត្រូវ | ពេលវេលានៃការចុះតាមដាន | ធនធានដែលត្រូវការ |
|---|---|---|---|---|---|---|
| | | | | | | |

- ពង្រឹង និងពង្រីកកសិករបន្ថែម
- **<u>កសិករ និង កម្មករ ខុសគ្នាយ៉ាងម៉េច?</u>** កសិករគឺជាម្ចាស់ ចង់សំរាកពេលណាក៏បាន តែកម្មករបើរោងចក្របិទអស់ការងារធ្វើហើយ មកនៅភ្នំពេញយូរទៅលែងចេះកាន់ចបហើយ ទៅស្រុកម្តងលក់ដីម្តងបន្តិច គាត់វិវត្តន៍ពីកសិករមកកម្មករ។ ភាពជាម្ចាស់មកខ្ញុំគេ។
- **<u>ស្រូវ ប.រ.ស:</u>** កត់ត្រាពីថ្ងៃសាប ដាក់ដី ច្រូត ដក ស្ទូង ទំហំដី ចំនួនពូជដែលប្រើ រយ: ពេលប៉ុន្មាន ចំនួនដើមស្រូវដែលស្ទូង ការបែកគុម្ព ទិន្នផល..។

**ការបង្ហាញពីការចុះភូមិ:**

១ – កសិករ **សុខ រឿន** ភូមិព្រែន ឃុំព្រៃគុយ ស្រុកកំពង់ស្វាយ មានផ្ទៃដី ៤០ម គុណ ២៥ ម នៅលើដីរបស់គាត់មានសួនដំនាំ២ ជង្រុកស្រូវ ទ្រុងមាន់ ទ្រុងជ្រូក អណ្តូងទឹក ទ្រុងដី។

២– កសិករ **អ៊ឹម យាន់** ភូមិស្រយ៉ូងជើង ឃុំស្រយ៉ូវ មានផ្ទៃដី ២៥ម គុណ៤០ម នៅលើដីរបស់គាត់មានប្រលាយទឹក១ ខ្សែ សួនដំណាំ២ ស្រះទឹកចិញ្ចឹមត្រី៣ប្រភេទ ទ្រុងមាន់ រោងជន្លេនក្រហម ។ ដើរស៊ីឈ្នួលដាំដំណាំឱ្យគេ ១ថ្ងៃ ១២០០០ ត ដើមដំណាំយុទ្ធសាស្ត្រ។

៣ –កសិករ **អ៊ុន អាត** ភូមិអន្លង់លោក ឃុំព្រៃគុយ មានផ្ទៃដី ៣៥ម គុណ ៣០ម នៅលើដីរបស់គាត់មានសួនដំណាំ២ ទ្រុងមាន់ ទ្រុងជ្រូក ឡឧស្ម័ន ស្រះទឹក អណ្តូងទឹក។

**<u>យើងត្រូវទៅមើលលើអ្វីខ្លះ?</u>**

- មើលសួនពហុប្រយោជន៍
- មើលផែនទីក្តីស្រម៉ៃ

- អនុវត្តផ្ទាល់ជាមួយកសិករពីជី និងថ្នាំធម្មជាតិ (កំប៉ុស្តគោក កំប៉ុស្តទឹក និង អ៊ីអឹម)
- អាហារត្រូវវេចខ្ចប់យកទៅហូបនៅភូមិ
    - **ភូមិអន្លង់លោក:** ឈើវិត កែវស្រីពៅ វិតអេត ទូចស្រីមួយ ង៉ែតសុផន អ៊ុងឈុំ ឯករ៉ម ប៉ុលទ្រី ប៉ុលស៊ីនួន ស៊ិនស៊ីណន (ស្រី៥)។ **ប្រធានក្រុម ស៊ិន ស៊ីណន**
    - **ភូមិព្រៃ:** ម៉ីននាង ណមពៅ អោភក្តី ស៊ិនវាសនា ពុំលី អិនអ៊ុន ឌុកស៊ីនិន ស៊ុំមទុង សុខរឿន កែវសុមន្ថា (ស្រី៤)។ **ប្រធានក្រុម សុមន្ថា**
    - **ភូមិស្រយ៉ូងជើង:** ដែងសារឿត វ៉ុរហុង សួងសុភាព ឡុងជ្រាប កែវគង់នៅ ឈិតហួរ អ៊ិតស៊ុណា សាន់សារី សឿនរិទ្ធី ប៉ាល់យឿន អ៊ូតឡុង ឆឹមគឹមហេន (ស្រី៣)។ **ប្រធានក្រុម ដែង សារឿត**
        - ធ្វើកំណត់ហេតុ និងរបាយការណ៍ត្រលប់មកវិញដើម្បីបង្ហាញ
        - ចេញដំណើរម៉ោង ៧:០០ព្រឹក (ជិះឡាន)
        - ខ្ចប់បាយទៅដោយខ្លួនឯងទាំង ៣ក្រុម
        - ជួបជុំគ្នាវិញនៅម៉ោង ១:៣០–២:០០
        - ជួបជុំគ្នាវិញបង្ហាញលទ្ធផលពីចំនុចខ្លាំង ចំនុចខ្សោយ មេរៀនដែលរៀនបាន ភ្ជាប់ជាមួយផែនទីក្តីស្រម៉ៃរៀងៗខ្លួនមក
        - តំណាងក្រុមយកក្រដាស ហ្វីត សំរាប់ពិភាក្សាក្រុមតាមក្រុមនីមួយៗ

ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១១

**<u>ការឆ្លុះបញ្ចាំងពីការចុះភូមិ:</u>**

- ប្រើដីអស់លទ្ធភាព
- ដាំដំណាំងាយៗ
- បានចំណូលឱ្យកូនរៀន ហូបចុក មានធ្វើជីធម្មជាតិ
- សំរាប់កសិករជនបទដាំ និងចិញ្ចឹមបានសមរម្យ មានការពង្រីកដល់ក្រុមថ្មីទៀត
- សប្បាយរីករាយ ហើយនឹងគូរផែនទីក្តីស្រម៉ៃបន្ថែមទៀត

➡ **ក្រុមទី២: សមាជិក ១២នាក់ ស្រី៣នាក់ ភូមិស្រយ៉ូវជើង ឃុំស្រយ៉ូវ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ កសិករឈ្មោះ អ៊ុំម ឃាន់** មានកូនចំនួន ៤នាក់ ស្រី២នាក់ មានផ្ទៃដី ២៥ម គុណ៥០ម។

**<u>លទ្ធផលដែលបានរៀនសូត្រ:</u>**

- ស្លួនពហុប្រយោជន៍:



  - ដំណាំយុទ្ធសាស្ត្រ មាន២១មុខ: (ត្រៀប ល្ហុង ចេក ស្វាយ ខ្នុរ ស្លា ល្មុត ត្រៀបបារាំង ទឹកដោះគោ កន្ទឹមក្រហម កំពីងរាជ ខ្ទិត ដកម៉ៃ ភ្ញៀវ ក្រូចឆ្មា ក្រូចថ្លុង ក្រូចចិន ដូង ស្រកានាគ អង្គាដី ជំពូ កន្ទួត)។
  - ដំណាំគ្រឿងទេស: ស្លឹកគ្រៃ រំដេង ល្មៀត ជី ម្ទេស ម្រះព្រៅ ម្អម។
  - ដំណាំបន្លែរិលជុំ: ម្រះ ភ្លៅកង្កែប ននោង ឃ្លោក ត្រប់ ត្រកួន អំពៅ ដំលូងមី ស្លឹកងុប ស្លឹកបាស់។
  - រុក្ខជាតិសំរាប់ធ្វើថ្នាំ និងជី: ស្ដៅ ក្ដូច កន្ទុំថេត។
  - ការចិញ្ចឹមសត្វ: ចិញ្ចឹមមាន់ ជន្លេន គោ ត្រី (ត្រីមាន២ស្រះ ត្រីកាប ឡាបយ៉ា ឆ្ពិន ព្រលូង ត្រីប្រា ក្អក់ ត្រី អណ្ដែង កំភ្លៀញ ត្រីក្រាញ់ ដោយប្រើចំណីធម្មជាតិ មានកន្ទក់ បាយ កណ្ដៀរ ជន្លេន ត្រកួន)។
  - វិធីធ្វើជី និងថ្នាំ: ជីកំប៉ុស្តគោក និងមេជីអុីអឹម។
  - វិធីបង្កាត់ឈើហូបផ្លែ (តត្រួយ)។

- ពង្រីកកសិករបាន ៥នាក់ ហើយពី៥នាក់ ទៅ២៥នាក់។
- ចំណាយចំណូលរបស់គាត់ ស្មើគ្នា (ក្នុងមួយចំណាយ និងចំណូល ជាមធ្យម ៨–៩ពាន់រៀល)។
- ស្ថានភាពគ្រួសាររបស់គាត់ពីមុនឆ្នាំ ២០០៦ដីនៅទំនេរ ដីខាងក្រោយភូមិប្រវែង២០ម គុណ ៥០ម ប្រចាំគេ២០មុឺន ធ្វើការចំណាកស្រុក។ តែ២០០៨–២០១១ មានការផ្លាស់ប្ដូរកែប្រែការប្រើដី យកដីមកវិញ ហើយលែងចំណាកស្រុក។
- មានការគាំទ្រពីអង្គការហ្វូម លើបច្ចេកទេស សំភារៈ និងទុន។
- មានការគាំទ្រពីអាជ្ញាធរមូលដ្ឋាន។
- ឆន្ទៈរបស់កសិករ ផ្ទះមានអនាម័យល្អ។
- គាត់ប្រើប្រាស់ធនធានធម្មជាតិទាំងអស់ ដែលមាននៅជុំវិញផ្ទះ។
- ចំនុចខ្វះខាត:
  - ក្រោលគោរជាប់នឹងផ្ទះដោយសារកន្លែងចង្អៀតទឹកលិច។
  - មិនបានជំរុញកូនឱ្យចូលរៀន២នាក់ ដោយខ្វះខាតតាំងពីមុនមក (ចំណាកស្រុក)។
  - អត់មានផែនទីដាក់ស្ដែង។

- អនុសាសន៍:
  - o គួរតែរកឱកាសជំរុញកូនឱ្យបានចូលរៀនវិញ។

**ក្រុមទី១: សមាជិក ១០នាក់ ស្រី៤នាក់ ផ្ទះលោកសុខ រឿន ភូមិព្រៃន ឃុំព្រៃគុយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។** គោលបំណងរបស់ក្រុម: ផែនទីក្តីស្រមៃ២០០៩ សួនពហុប្រយោជន៍ ការអនុវត្តផ្ទាល់(កំប៉ុស្តគោក កំប៉ុស្តទឹក អ៊ីអឹម)។



- o ផែនទីរបស់គាត់ គាត់បានរក្សាទុកជាឯកសារសំរាប់ឱ្យកសិករគំរូរជំនាន់ក្រោយមើល
- o នៅលើផែនទីរបស់គាត់ខាងកើត លិច ជើង ត្បូង ពិតជាមានដូចនៅក្នុងផែនទីមែន
- o សួនពហុប្រយោជន៍របស់គាត់បច្ចុប្បន្នមានដី៧អា ៧០០ម៉ែត្រការ៉េ ទំហំ៣ម គុណ៤ម នៅជាប់ផ្ទះមានរោងម៉ាស៊ីនកិនស្រូវមួយ។
- o ផ្នែកខាងកើតផ្ទះមានអំពៅ១៣ជួរក្នុងមួយជួរ៧គុម្ពក្នុងមួយគុម្ព៣ដើម នៅក្នុងអំពៅមានម្ទេស ជីស្លឹកគ្រៃ រំដេង ហើយមានអណ្តូងទឹកមួយ លើអណ្តូងទឹកមានត្រឡាចននោង នៅក្បែរអណ្តូងទឹកមានធុងចំរោះហាកា។
- o ផ្នែកខាងជើងផ្ទះមានត្រាវ ជង្រុកស្រូវផ្ទាល់ខ្លួន ជង្រុកស្រូវសហគមន៍ ចន្លោះផ្ទះផ្នែកខាងជើងមានទ្រើងននោងប្រវែងទទឹង៤ម បណ្តោយ១៥ម ដើមចេក ទ្រុងមាន់ ទ្រុងជ្រូក រណ្តៅដីកំប៉ុស្ត ពុំនូកចំបើង បង្គន់អនាម័យ។
- o ផ្នែកខាងលិចផ្ទះលើផ្ទៃដីសួនដំណាំមាន ដំលូងមី ពពាយ ស្វាយចន្ទី ដូង កន្ទុំថេត ត្រប់២០០គុម្ព ខ្ទឹមដើមព្រីង ស្វាយ អង្ការដី។
- o នៅលើរបងព័ទ្ធសួនមានស្លឹកបាស់ ននោង នៅព័ទ្ធជុំវិញដីប្លង់ផ្ទះមានរបងរស់ (ល្ហុងខ្វង ដើមដូង ត្នោត កន្ទុំថេត)។
- o ការអនុវត្តផ្ទាល់របស់ក្រុម (អ៊ីអឹម កំប៉ុស្តទឹក កំប៉ុស្តគោក)

- ចំនុចខ្លាំង: ការប្រើប្រាស់ដីអស់លទ្ធភាព គ្រួសារមានបន្លែហូបគ្រប់គ្រាន់លក់នៅលើទីផ្សារ មានចំនូលសំរាប់ផ្គត់ផ្គង់គ្រួសារ មួយខែគិតជាមធ្យម ៥០០០០រៀល ក្លាយជាអ្នកសម្របសម្រួលដល់កសិករគំរូរផ្នែកកសិកម្មបែបធម្មជាតិ ។
- ចំនុចខ្សោយ: ខ្វះអនាម័យ ជុំវិញផ្ទះ ការលាយច្របល់ដី សំភារៈប្រើប្រាស់។
- ក្តីរំពឹងទុករបស់កសិករក្រុមទី១: វិលត្រលប់ទៅវិញយកចំណេះដឹងទៅអនុវត្ត និងចែករំលែកដល់សហគមន៍។

**ក្រុមទី៣: ភូមិអន្លង់លោក កសិករឈ្មោះ អ៊ុន អាត ដែលមានសមាជិក១១នាក់ ស្រីឯនាក់មកពី ០៦ អង្គការ។**

- ចំនុចល្អ: គាត់មានសួនពហុប្រយោជន៍ដូចដែលយើងបានគ្រោងទុកពិតមែនមានដូចជា ដំនាំហូបផ្លែ បន្លែ ចំរុះ ការចិញ្ចឹមសត្វ (មាន់និងស្រះត្រី) សរុបបន្លែ២៥មុខ។
- ការធ្វើជីធម្មជាតិមាន ជីកំប៉ុស្តគោក កំប៉ុស្តទឹក អ៊ីអឹម ទ្រុងគោ ពិសេសគាត់បានបន្ថែមពីថ្នាំធម្មជាតិការពារជំងឺមាន់ទៀតផង។
- ចំណែកផែនទីក្តីស្រម៉ៃរបស់គាត់ គាត់ធ្វើបានសំរេច មិនតែប៉ុណ្ណោះបានសំរេចច្រើនជាងផែនការដែលបានគ្រោងទុកលើផែនទីដែលគាត់មាន។
- គាត់បានបង្ហាញបទពិសោធន៍នៃការដាំបន្លែ និងការអនុវត្តផ្ទាល់នៃការធ្វើជីអ៊ីអឹម កំប៉ុស្តគោក ទឹក ធ្វើទ្រុងមាន់ ការបែងចែកដីផ្ទះទៅតាមតំរូវការកសិករឱ្យក្លាយជាសួនពហុប្រយោជន៍។
- មានមាន់សរុបទាំងអស់ ៦០ក្បាល។
- ចំនុចខ្វះខាត: ដីសួនដាំបន្លែមិនទាន់អស់ វិលជុំ
- បញ្ចេញកំលាំងតែម្នាក់ឯង
- ដីមាត់ស្រះនៅទំនេរ
- មានតែទ្រុងជ្រូក តែមិនទាន់មានជ្រូកទេ
- គួរតែធ្វើទ្រុងជីកំប៉ុស្តគោក
- ចំនុចកែលំអរ: គួរតែទិញជ្រូកដាក់ឱ្យទាន់ពេល
- ចែករំលែកកំលាំងពលកម្មទៅសមាជិកគ្រួសារផង
- បំពេញបន្ថែមបន្លែវិលជុំតាមមាត់ស្រះ
- គួរតែជីករណ្តៅធ្វើជីកំប៉ុស្តគោក

បន្ទាប់មកយើងបានបន្តឱ្យកសិករទាំងអស់យកផែនទីក្តីស្រម៉ៃរបស់ខ្លួន មកកែតំរូវត្រង់ចំនុចដែលចង់កែលំអរ និងបានបង្ហាញពីការធ្វើផែនការបន្តរយៈពេល ៦ខែ (០៩/២០១១-០២/២០១២) ដល់កសិករ ដើម្បីធ្វើផែនការរៀងៗខ្លួន។

**ផែនការសកម្មភាពរបស់កសិករ ធ្វើតាមចិត្តខ្លួនឯង ឬធ្វើតាមផែនទីក្តីស្រម៉ៃ?**

**ទំរង់ផែនការសកម្មភាព:** ចំពោះធនធានខាងក្រៅយើងត្រូវពិភាក្សាជាមួយអង្គការ ហើយបុគ្គលិកអង្គការត្រូវរៀបចំផែនការនេះដើម្បីដាក់បញ្ចូលទៅក្នុងសកម្មភាពឆ្នាំ២០១២ ដើម្បីគាំទ្រពួកគាត់។

| ល.រ | សកម្មភាព | ដំណើការ | ពេលវេលា | ទីកន្លែង | ធនធាន | | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|
| | | | | | ខាងក្នុង | ខាងក្រៅ | |
| ១ | | | | | | | |
| ២ | | | | | | | |
| ៣ | | | | | | | |
| ៤ | | | | | | | |

បានឃើញ...... ថ្ងៃទី...... ខែ........ ឆ្នាំ........

មន្រ្តីកម្មវិធី អ្នកធ្វើផែនការ

ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១១

## បន្តធ្វើផែនការសកម្មភាព

កសិករនិមួយៗ បន្តធ្វើផែនការសកម្មភាព និងគូផែនទីក្តីស្រមៃរបស់គាត់។ បន្ទាប់មកបុគ្គលិកតំណាងអង្គការទាំងប្រាំ បានយកផែនការសកម្មភាពរបស់កសិករនិមួយៗដែលបានធ្វើរួច មកត្រួតពិនិត្យ និងធ្វើការកែលំអ ហើយចុះហត្ថលេខាទទួលស្គាល់។ អ្នកស្រី ស៊ីណន បានប្រមូលផែនការសកម្មភាពទាំងអស់មករក្សាទុកច្បាប់ដើម ហើយថតចំលងជូនកសិករនិមួយៗសំរាប់អោយគាត់អនុវត្តតាមផែនការរបស់គាត់។

## រំលឹកមេរៀនបីថ្ងៃកន្លងមក

អ្នកស្រី ស៊ីណន រំលឹកមេរៀនតាំងពីថ្ងៃទីមួយ រហូតដល់ថ្ងៃទីបី។ សិក្ខាកាមភាគច្រើនចូលរួមឆ្លើយយ៉ាងស្វាហាប់ មានន័យថាសិក្ខាកាមយល់ច្បាស់ពីមេរៀនដែលអ្នកសម្របសម្រួលបានចែករំលែករយៈពេលបីថ្ងៃកន្លងមក។ និងវិធីសាស្រ្តពង្រីកកសិករបន្តទៀត។

## វាយតម្លៃវគ្គទាំងមូល

អ្នកស្រី ស៊ីណន ពន្យល់ពីរបៀបវាយតម្លៃវគ្គទាំងមូល ដើម្បីឆ្លុះបញ្ចាំងពីវគ្គ នឹងកែលំអរវគ្គក្រោយៗទៀត។ សិក្ខាកាមទាំងអស់បានចូលរួមវាយតម្លៃទាំងអស់គ្នា ដែលមានលទ្ធផលល្អគាគច្រើន ។

អ្នកស្រី មិត្ត សុមន្ថា ឡើងឆ្លុះបញ្ចាំងពីវគ្គទាំងមូល និងចែករំលែកពីទស្សនវិស័យរបស់ អង្គការអាក់សិនអេតកម្ពុជា។ គោលបំណងរបស់អង្គការ អាក់សិនអេតកម្ពុជា គឺជួយកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ អង្គការបានកំពុងធ្វើការងារជាមួយ ១៩ អង្គការដៃគូ នៅក្នុងខេត្តចំនួន ១៥ ហើយគំរោងពង្រឹងផ្នែកកសិកម្មដល់កសិករនេះ ជាគំរោងមួយក្នុងចំណោមគំរោងដ៏ទៃទៀតដែលអង្គការកំពុងតែអនុវត្តជាមួយអង្គការដៃគូនៅតាមខេត្ត។

អ្នកស្រី មានសេចក្តីរីករាយយ៉ាងខ្លាំងដោយឃើញសិក្ខាកាមទាំងអស់ បានចូលរួមយ៉ាងស្វិតស្វាញជាមួយការចែករំលែក ពីសំណាក់អ្នកសម្របសម្រួល ជាពិសេសនៅថ្ងៃទីបី ដែលសិក្ខាកាមបានធ្វើទស្សនកិច្ចសិក្សា និងអនុវត្តផ្ទាល់ពីអ្វីដែលបានរៀនពីថ្ងៃកន្លងមក។ អ្នកស្រីសង្ឃឹមទុកយ៉ាងមុតមាំថា សិក្ខាកាមកសិករក្រុម៣ នេះ នឹងព្យាយាមអនុវត្តតាមផែនការសកម្មភាពរយៈពេល ៦ខែ ដែលខ្លួនទើបតែធ្វើពីព្រឹកមិញនេះអោយបានសម្រេច ហើយនិងធ្វើផែនការបន្តទៀតជាមួយសាមីអង្គការសម្រាប់រយៈពេលបន្ត។ ហើយអ្នកស្រីជឿជាក់ថាក្រុមបីនេះនឹងក្លាយជា ជាកសិករគំរូ ដូច ពូ ឡុង និង ពូ រឿន គ្រប់ៗគ្នា ដើម្បីជួយខ្លួនឯងផង នឹងជួយកសិករផ្សេងៗទៀតនៅក្នុងសហគមន៍យើងទាំងអស់គ្នាផងដែរ។

អ្នកសម្របសម្រួលទាំងអស់នឹងតំណាងសិក្ខាកាម ក៏បានឡើងបញ្ចេញមតិយោបល់ឆ្លុះបញ្ចាំងពីវគ្គផងដែរ។

ខេត្តកំពង់ធំ ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១១

អ្នកធ្វើរបាយការណ៍

**ឆឹម គឹមហេន**